# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាបុណ្យព្រះវិញ្ញាណយាងមក
# ផ្សារតូច ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៩
## ពិភពមួយដែលគ្មានព្រះជាម្ចាស់ជាពិភពដែលគ្មានព្រលឹង

**អត្ថបទទី១៖ កិច្ចការ ២,១-១១**

ពួកសាវ័កបានឃើញហាក់ដូចជាមានអណ្ដាតភ្លើងបែកចេញពីគ្នា ចុះមកសណ្ឋិតលើពួកគេម្នាក់ៗ។ កក ២,៣

**អត្ថបទទី២៖ រ៉ូម ៨,៨-១៧**

ប្រសិនបើបងប្អូនរស់នៅតាមលោកីយ៍ បងប្អូននឹងត្រូវស្លាប់ជាមិនខាន ផ្ទុយទៅវិញ ប្រសិនបើបងប្អូនពឹងផ្អែកលើព្រះវិញ្ញាណ ដើម្បីរំលាយរបៀបរស់នៅតាមលោកីយ៍ បងប្អូនមុខតែមានជីវិត។ រម ៨,១៣

**ដំណឹងល្អ៖ យ៉ូហាន ១៤,១៥-១៦.២៣-២៦**

ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «អ្នកណាស្រឡាញ់ខ្ញុំអ្នកនោះនឹងប្រតិបត្តិតាមពាក្យខ្ញុំ។ ព្រះបិតាខ្ញុំនឹងស្រឡាញ់អ្នកនោះ ហើយព្រះបិតា និងខ្ញុំ ក៏នឹងមកតាំងលំនៅ នៅក្នុងអ្នកនោះដែរ។ យហ ១៤,២៣

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ ជាថ្ងៃដ៏ពិសេសជាថ្ងៃទី៥០ដែលព្រះយេស៊ូបំពេញតាមពាក្យសន្យារបស់ព្រះអង្គ គឺផ្ញើព្រះវិញ្ញាណដ៏វិសុទ្ធមកសណ្ឋិតលើយើង ដើម្បីឲ្យយើងទៅមុខនៅក្នុងជីវិតជាគ្រីស្តបរិស័ទ។ នៅក្នុងគម្ពីរដំណឹងល្អ ព្រះយេស៊ូមានព្រះបន្ទូលថា "**ព្រះបិតានឹងខ្ញុំស្រឡាញ់អ្នកនោះ ហើយព្រះបិតានិងខ្ញុំក៏នឹងមកតាំងលំនៅនៅក្នុងអ្នកនោះដែរ**"។ ព្រះបិតានឹងខ្ញុំស្រឡាញ់បងប្អូនទាំងអស់ និងព្រះបិតានិងខ្ញុំបានសម្រេចចិត្តបង្កើតព្រះដំណាក់របស់ព្រះអង្គ នៅក្នុងដួងចិត្តរបស់យើងម្នាក់ៗ។ **តើពាក្យនេះមានអត្ថន័យយ៉ាងណាសម្រាប់ជីវិតរបស់យើងផ្ទាល់?** ព្រះយេស៊ូផ្ទាល់ ព្រះបិតាផ្ទាល់រួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធផ្ទាល់បានសាងសង់ផ្ទះមួយយ៉ាងពិសេស នៅក្នុងដួងចិត្តរបស់យើង នៅក្នុងជីវិតរបស់យើង។ នៅពេលយើងឮដូចនេះយើងអាចសួរថា **តើព្រះជាម្ចាស់ជានរណា ដើម្បីស្រឡាញ់យើងយ៉ាងហ្នឹង?** ពិតមែនគឺព្រះយេស៊ូមានព្រះបន្ទូលថា "**ព្រះបិតា ព្រះបុត្រា ព្រះវិញ្ញាណដ៏វិសុទ្ធ យាងមកសាងសង់ផ្ទះមួយនៅក្នុងដួងចិត្តរបស់យើងផ្ទាល់**"។ យើងនឹកឃើញដល់រឿងលោកសាខេ ព្រះយេស៊ូបានទតឃើញលោកសាខេនៅលើដើមឈើ ហើយព្រះអង្គមានព្រះបន្ទូលថា "**ថ្ងៃនេះលោកពោរពេញដោយអំណរសប្បាយ ដោយសារខ្ញុំសុំទៅផ្ទះលោកខ្ញុំសុំទៅសួរសុខទុក្ខលោកនៅផ្ទះលោកហើយ**"។ លោកសាខេ ដែលជាមនុស្សពោរពេញដោយ

អំពើបាប ជាមនុស្សដែលធ្លាប់មើលងាយអ្នកក្រីក្រ ជាអ្នកធ្លាប់យកពន្ធយ៉ាងច្រើន ព្រះយេស៊ូបាន ជ្រើសរើសគាត់ដើម្បីទៅសួរសុខទុក្ខដល់ផ្ទះរបស់គាត់។

យើងទាំងអស់គ្នាជាមនុស្សដែលមានបាប ប្រហែលពេលខ្លះយើងគិតខ្លួនឯងថា **តើខ្ញុំមានឋានៈអ្វីដើម្បីឲ្យព្រះជាម្ចាស់មកសួរសុខទុក្ខខ្ញុំនៅក្នុងដួងចិត្តរបស់ខ្ញុំ?** មិនមែនតែសួរសុខទុក្ខទេ ព្រះជាម្ចាស់យាងមក ដើម្បីសាងសង់ទីលំនៅរបស់ព្រះអង្គនៅក្នុងដួងចិត្តរបស់ខ្ញុំ។ ដូចព្រះនាងម៉ារីបានសួរដល់ទេវទូតកាព្រីអែលដែរ **តើព្រះជាម្ចាស់ជានរណាដើម្បីស្រឡាញ់យើងយ៉ាងហ្នឹង?** នៅពេលព្រះជាម្ចាស់បានបង្កើតពិភពលោកអស់ហើយ នៅពេលមនុស្សបានប្រព្រឹត្តអំពើបាប មនុស្សបានជួបជុំគ្នាហើយសាងសង់កំពូលមួយយ៉ាងខ្ពស់បំផុត ដើម្បីបង្ហាញថាយើងមានអំណាចលើសព្រះជាម្ចាស់។ នៅពេលនោះ ព្រះជាម្ចាស់ឲ្យមនុស្សបាក់បែកគ្នា ឲ្យនិយាយភាសាខុសៗគ្នា ដើម្បីកុំឲ្យមនុស្សយើងពោរពេញដោយអំនួតដែលចង់ធំជាងព្រះជាម្ចាស់។ ប៉ុន្តែថ្ងៃនេះជាថ្ងៃដែលព្រះវិញ្ញាណដ៏វិសុទ្ធយាងមក ណែនាំឲ្យមនុស្សដែលនិយាយភាសាខុសៗគ្នាអាចស្តាប់គ្នាបាន អាចធ្វើដំណើរជាមួយគ្នាបាន។ ថ្ងៃនេះ ជាថ្ងៃដែលព្រះជាម្ចាស់សុខចិត្តសណ្ឋិតនៅក្នុងជីវិតរបស់យើង ដើម្បីឲ្យយើងរួបរួមគ្នាជាអង្គតែមួយនៅក្នុងព្រះបិតា នៅក្នុងធម៌មេត្តាករុណាដែលគ្មានព្រំដែនរបស់ព្រះជាម្ចាស់។

ពិតមែន ព្រះជាម្ចាស់បានបង្កើតយើងជាបុរសជាស្ត្រី ដែលមានលក្ខណៈដូចព្រះអង្គ ដែលជាតំណាងរបស់ព្រះជាម្ចាស់លើផែនដីនេះ ដោយសារព្រះជាម្ចាស់បានសម្រេចចិត្ត យកយើងជាបុរសជាស្ត្រីដើម្បីតាំងទីលំនៅរបស់ព្រះអង្គលើផែនដីនេះ។ ដោយកំពូលប៉ាប៉ែល មនុស្សបានយកចិត្តទុកដាក់ខិតខំបំផ្លាញការត្រាស់ហៅដ៏ពិសេសរបស់មនុស្ស មានន័យថាភ្ជាប់ជាមួយព្រះជាម្ចាស់តែម្តង។ **សព្វថ្ងៃតើមនុស្សយើងធ្វើដូចម្តេចដើម្បីរស់នៅជាមួយព្រះជាម្ចាស់ ដើម្បីជាប់ជាមួយព្រះជាម្ចាស់?** នៅក្នុងទីក្រុងរបស់យើង ពីមួយថ្ងៃទៅមួយថ្ងៃយើងខិតខំសាងសង់អាគារខ្ពស់ទៅៗ យើងមានកន្លែងយ៉ាងច្រើនដែលណែនាំឲ្យយើងភ្លេចវត្តមានរបស់ព្រះជាម្ចាស់។ នៅក្នុងជីវិតរបស់យើង នៅក្នុងទីក្រុង នៅក្នុងប្រទេសរបស់យើង មានកន្លែងយ៉ាងច្រើនដែលណែនាំឲ្យយើងភ្លេចវត្តមានរបស់ព្រះជាម្ចាស់ ដោយដឹងថាមនុស្សយើងរកឃើញសុភមង្គលដោយទីពឹងលើខ្លួនឯងបាន មនុស្សយើងអាចសាងសង់ជីវិតផ្ទាល់ខ្លួនដោយទីពឹងលើខ្លួនឯងបាន។ ប៉ុន្តែសង្គមមួយ ពិភពលោកមួយ ដែលគ្មានព្រះជាម្ចាស់ ជាសង្គមមួយ ពិភពលោកមួយដែលគ្មានព្រលឹង សង្គមមួយ ពិភពមួយ ដែលគ្មានជីវិតសក្ការៈ ជាសង្គមមួយ ពិភពមួយដែលជិតផុតដង្ហើម។ ដូច្នេះសម្រាប់យើងជាគ្រីស្តបរិស័ទ ឲ្យយើងយកចិត្តទុកដាក់ថ្វាយបង្គំ ស្រឡាញ់ អធិដ្ឋាន ដល់

ព្រះជាម្ចាស់ដោយសេចក្តីពិត នៅក្នុងសកម្មភាពជាក់ស្តែងប្រចាំថ្ងៃ ដោយសារព្រះជាម្ចាស់តាំងទីលំនៅនៅក្នុងដួងចិត្តរបស់យើង។

"**ឱព្រះអង្គម្ចាស់អើយ! ព្រះអង្គគង់នៅក្នុងដួងចិត្តរបស់ខ្ញុំពិតមែន ហេតុនេះហើយសូមព្រះអង្គអនុញ្ញាតឲ្យខ្ញុំចូលនៅក្នុងដួងចិត្តរបស់ខ្ញុំ ដើម្បីជួបជាមួយព្រះអង្គដែលគង់នៅរួចហើយ**"។ ពិតមែនព្រះជាម្ចាស់គង់នៅក្នុងដួងចិត្តយើងហើយ ប៉ុន្តែជាយើងដែលជួនកាលភ្លេចវត្តមានរបស់ព្រះជាម្ចាស់ ដែលបានសាងសង់ទីលំនៅនៅក្នុងដួងចិត្តរបស់យើង។

នៅពេលយើងនឹកឃើញព្រះជាម្ចាស់ ដែលសុខចិត្តសាងសង់ទីលំនៅនៅក្នុងដួងចិត្តរបស់យើង យើងអាចនិយាយថាយើងពោរពេញដោយតម្លៃថ្លៃថ្នូរណាស់។ មនុស្សយើងជានរណាដើម្បីឲ្យព្រះជាម្ចាស់ស្រឡាញ់យើងយ៉ាងហ្នឹង? ជីវិតនីមួយៗរបស់បងប្អូនទាំងអស់ បីដូចជាព្រះដំណាក់ដ៏តូចមួយរបស់ព្រះជាម្ចាស់។ នៅថ្ងៃដែលព្រះវិញ្ញាណដ៏វិសុទ្ធយាងមក យើងបានឃើញអណ្តាតភ្លើងលើក្បាលរបស់ក្រុមគ្រីស្តទូតម្នាក់ៗ អណ្តាតភ្លើងលើក្បាលព្រះនាងម៉ារី និងសាវ័កមួយចំនួន នៅពេលនោះគេភ្ញាក់ គេភ័យខ្លាច ប៉ុន្តែអណ្តាតភ្លើងនេះជាពន្លឺមួយដែលណែនាំឲ្យគេទទួលជីវិតថ្មី។ សព្វថ្ងៃ តើយើងដែលជាគ្រីស្តបរិស័ទមើលឃើញភ្លើងដ៏តូចដែលភ្លឺនៅក្នុងដួងចិត្តរបស់យើង ដើម្បីរំឭកថានៅពេលនេះព្រះជាម្ចាស់គង់នៅជាមួយយើងពិតមែន ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធភ្ជាប់នឹងសណ្ឋិតលើយើង។

បន្តិចទៀតខ្ញុំធ្វើអគ្គសញ្ញាលាបថ្វាសដល់បងប្អូន២០នាក់ នៅពេលនោះខ្ញុំនិយាយថា "**ខ្ញុំសុំដៅ... ដោយព្រះវិញ្ញាណដ៏វិសុទ្ធដែលជាអំណោយទានរបស់ព្រះជាម្ចាស់**"។ ពិតមែនថ្ងៃនេះព្រះវិញ្ញាណដ៏វិសុទ្ធយាងចូលនៅក្នុងវិញ្ញាណដ៏ទន់ខ្សោយរបស់យើង ដែលជួនកាលវង្វេង ដែលខ្វះកម្លាំង ព្រះវិញ្ញាណដ៏វិសុទ្ធផ្ទាល់បានភ្ជាប់នឹងវិញ្ញាណរបស់យើង ដើម្បីឲ្យយើងពោរពេញដោយរស្មី និងប្រាជ្ញាឈ្លៀសវៃ ដើម្បីឲ្យយើងដឹងខុសដឹងត្រូវ ដើម្បីឲ្យយើងពោរពេញដោយសេចក្តីក្លាហានអង់អាច ដើម្បីឲ្យយើងមានយោបល់ល្អ ដើម្បីឲ្យយើងពោរពេញដោយចិត្តធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដើម្បីឲ្យយើងកោតខ្លាចព្រះជាម្ចាស់ ដោយគោរពព្រះជាម្ចាស់នៅក្នុងជីវិតរបស់យើងជានិច្ច ដោយសារយើងជាបុត្រាបុត្រីរបស់ព្រះអង្គ យើងជាបុរសជាស្ត្រីរបស់ព្រះជាម្ចាស់ផ្ទាល់។ យើងអាចមើលឃើញវត្តមានរបស់ព្រះជាម្ចាស់ នៅក្នុងបងប្អូនទាំងអស់ដែលអង្គុយនៅទីនេះ និងនៅក្នុងបងប្អូនទាំងអស់ដែលយើងជួបជារៀងរាល់ថ្ងៃដែរ។ ហេតុនេះហើយឲ្យយើងសួរខ្លួនឯងថា **តើខ្ញុំមើលអ្នកដទៃរបៀបណា? តើខ្ញុំមើលជនបរទេសរបៀបណា? តើខ្ញុំមើលមនុស្សដែលខុសប្លែកពីខ្ញុំរបៀបណា? តើខ្ញុំមើលទារកនៅក្នុងផ្ទៃពោះម្តាយរបៀបណា? តើខ្ញុំ**

**ឃើញអ្នកពិការដែលដើរមិនរួចនៅលើគ្រែរបៀបណា? តើខ្ញុំមើលចាស់ជរាដែលបាត់បង់ស្មារតីរបៀបណា?**

ជីវិត ជាជីវិតដ៏សក្ការៈដែលយើងបានទទួលពីព្រះជាម្ចាស់ គ្រប់ដង្ហើមនៃជីវិតជាដង្ហើមរបស់ព្រះជាម្ចាស់ផ្ទាល់។ នៅពេលយើងមើលបងប្អូនឯទៀតៗ ពោរពេញដោយកម្លាំងក្តី អស់កម្លាំងក្តី យើងដឹងថាដង្ហើមដ៏តូចតាចមួយ ជាដង្ហើមដែលយើងបានទទួលពីព្រះជាម្ចាស់ផ្ទាល់។ ហេតុនេះហើយ ឲ្យយើងបើកចិត្តគំនិតរបស់យើងដល់បងប្អូនឯទៀតៗ ដើម្បីកសាងគ្រួសារដ៏ធំមួយ ពោរពេញដោយភាតរភាពដែលភ្ជាប់នឹងវត្តមានរបស់ព្រះជាម្ចាស់ ដែលបានតាំងទីលំនៅនៅក្នុងជីវិតរបស់យើង។

យើងជាព្រះដំណាក់របស់ព្រះជាម្ចាស់ ប៉ុន្តែមិនមែនជាព្រះដំណាក់ដែលណែនាំឲ្យយើងបិទទ្វារនៃដួងចិត្តរបស់យើងយ៉ាងចង្អៀតចង្អល់។ ដូចក្រុមគ្រីស្តទូតពីដើម គេភ័យខ្លាចគេនៅក្នុងបន្ទប់តូចមួយ បិទទ្វារ បិទបង្អួច ដោយសារខ្លាចមានទាហានមកចាប់គេ ដោយសារគេខ្លាចប្រកាសអំពីព្រះយេស៊ូមានព្រះជន្មថ្មីដ៏រុងរឿង ដោយសារគេខ្លាចជីវិតដែលគេបានទទួលពីព្រះជាម្ចាស់។ ដូច្នេះ ជីវិតដែលគេបានទទួលពិតមែនជាជីវិតមួយដែលគេទុកថែរក្សាយ៉ាងស្ងៀមស្ងាត់។ កុំឲ្យគ្រួសាររបស់យើង កុំឲ្យព្រះសហគមន៍របស់យើង កុំឲ្យសហគមរបស់យើងទៅជាកន្លែងចង្អៀតចង្អល់ដែលយើងបិទទ្វារ ដែលយើងបិទបង្អួច ផ្ទុយទៅវិញឲ្យយើងមើលនៅពេលព្រះវិញ្ញាណដ៏វិសុទ្ធយាងមកហើយក្រុមគ្រីស្តទូតចេញ ណែនាំដោយព្រះនាងម៉ារីផ្ទាល់ដើម្បីចែករំលែកដំណឹងល្អដ៏ពិសេសបំផុត។ ថ្ងៃនេះព្រះយេស៊ូមានព្រះជន្មគង់នៅ សូមស្រឡាញ់គ្នាទៅវិញទៅមកដូចព្រះយេស៊ូបានស្រឡាញ់យើងពិតមែន។ នៅពេលនោះទាំងទ្វារ ទាំងបង្អួចផ្ទុះអស់ហើយដោយសារកម្លាំងនៃព្រះវិញ្ញាណដ៏វិសុទ្ធ។ នៅក្នុងជីវិតរបស់យើងជួនកាលចង្អៀតចង្អល់ថ្ងៃនេះនៅក្រោមអំណាចនៃសេចក្តីស្រឡាញ់ ដោយកម្លាំងនៃព្រះវិញ្ញាណដ៏វិសុទ្ធឲ្យបេះដូងរបស់យើងផ្ទុះឡើង ដើម្បីណែនាំឲ្យព្រះវិញ្ញាណដ៏វិសុទ្ធពោរពេញដោយសេចក្តីស្រឡាញ់ដែលគ្មានព្រំដែនរបស់ព្រះជាម្ចាស់ យាងចូលនៅក្នុងដួងចិត្តរបស់យើង និងបណ្តេញយើងចេញពីផ្ទះ ចេញពីព្រះសហគមន៍ ចេញពីព្រះវិហារយើង ដើម្បីចេញទៅប្រកាសអំពីព្រះយេស៊ូដែលមានព្រះជន្មគង់នៅនៅថ្ងៃនេះ។

ថ្ងៃនេះព្រះវិញ្ញាណដ៏វិសុទ្ធ ណែនាំឲ្យយើងទៅដល់បងប្អូនឯទៀតៗដែលគ្មានទីពឹង ដែលគ្មានទីលំនៅ ដែលគ្មានតម្លៃដោយសារសង្គមយើងមិនចេះមើលគេសោះ។ ថ្ងៃនេះព្រះវិញ្ញាណដ៏វិសុទ្ធ ណែនាំឲ្យយើងទៅជាមនុស្សថ្មីដែលចេះមើលឃើញអ្វីៗទាំងអស់ដែលកើតឡើងនៅក្នុងសង្គមរបស់យើង ជាមួយអ្នកជិតខាងរបស់យើង កន្លែងដែលយើងធ្វើការ កន្លែងដែលយើងរស់

នៅ ដើម្បីណែនាំឲ្យសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ទៅដល់គេពិតមែន។ ប្រសិនបើយើងធ្វើដូច្នេះ ព្រះជាម្ចាស់ពោរពេញដោយអំណរសប្បាយ ដោយសារព្រះដំណាក់របស់ព្រះអង្គមិនមែនជាកន្លែងដ៏តូចមួយ ប៉ុន្តែទៅជាវិសាលវិហារធំបំផុតដើម្បីណែនាំឲ្យពន្លឺនិងខ្យល់នៃព្រះវិញ្ញាណដ៏វិសុទ្ធចេញចូលបាន នេះជាដំណាក់ដែលយើងត្រូវការសាងសង់សម្រាប់ព្រះជាម្ចាស់។ ទេវទូតថា "**បងប្អូនជាទីស្រឡាញ់ សូមកោតសរសើរព្រះជាម្ចាស់ សិរីរុងរឿងរបស់ព្រះអង្គនៅលើផែនដីផង នៅស្ថានបរមសុខផងយាងមកថ្ងៃនេះនៅលើផែនដី**" ឱព្រះវិញ្ញាណដ៏វិសុទ្ធសូមយាងមកដើម្បីតាំងទីលំនៅក្នុងដួងចិត្តរបស់យើង និងដើម្បីណែនាំឲ្យដួងចិត្តរបស់យើងផ្ទុះដោយកម្លាំងនៃព្រះវិញ្ញាណដ៏វិសុទ្ធ ឲ្យយើងបើកទ្វារ ឲ្យយើងបើកបង្អួច រួមជាមួយព្រះនាងម៉ារីដែលជាព្រះមហាក្សត្រីនៃក្រុមគ្រីស្តទូត សូមឲ្យយើងឈរឡើងដោយប្រកាសថា "**ខ្ញុំជាអ្នកបម្រើ ខ្ញុំត្រៀមខ្លួនជានិច្ចដើម្បីបម្រើ ដើម្បីស្រឡាញ់**" សូមឲ្យអំណរសប្បាយដែលព្រះវិញ្ញាណដ៏វិសុទ្ធយាងមកគង់នៅជាមួយបងប្អូនជានិច្ច។ អាម៉ែន៕ ជយោព្រះវិញ្ញាណដ៏វិសុទ្ធ៕